## សេចក្តីប្រកាសព័ត៌មានរួមរវាងក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
## និង អង្គការសុខភាពពិភពលោក

ភ្នំពេញ ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៩

**ក្រសួងសុខាភិបាលណែនាំ "ក្រុមដែលប្រឈមមុខ" អោយប្រុងប្រយ័ត្ន**
**ដោយករណីស្លាប់ពីការរាតត្បាតជាសកលនៃជំងឺផ្តាសាយថ្មី H1N1 កើនឡើងដល់ ៣ នាក់ក្នុងប្រទេសកម្ពុជា**

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជំរាបជូនដំណឹងដ៏គួអោយសោកស្តាយដល់សាធារណជនថាមានជនជាតិកម្ពុជា ពីរ នាក់ទៀតបានស្លាប់ ពីការរាតត្បាតជាសកលនៃជំងឺផ្តាសាយថ្មី H1N1 ដែលនាំអោយចំនួនសរុបនៃករណីស្លាប់ក្នុងប្រទេសកម្ពុជាកើនដល់ ៣ ករណី ។

អ្នកជំងឺមានអាយុ ៤៧ ឆ្នាំ ភេទ ប្រុស មកពីទីក្រុងភ្នំពេញបានចាប់ផ្តើមចេញរោគសញ្ញានៃជំងឺផ្តាសាយពីថ្ងៃទី ១៩ ខែ កញ្ញា ហើយបានស្វែងរកការព្យាបាល នៅគ្លីនិកឯកជននៅថ្ងៃច័ន្ទ ទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៩។ គាត់ត្រូវបានដាក់អោយចូលសំរាកនៅមន្ទីរពេទ្យកាល់ម៉ែតនៅថ្ងៃសុក្រទី ០២ ខែតុលា ឆ្នាំ ២០០៩ ដែលនៅទីនោះគាត់បានទទួលការព្យាបាលជាបន្ទាន់។ គាត់ត្រូវបានធ្វើរោគវិនិច្ឆ័យឃើញថាមានផ្ទុកវីរុសជំងឺផ្តាសាយប្រភេទថ្មី H1N1 នៅថ្ងៃទី ០៣ តុលា និង បានទទួលមរណៈភាពដោយសារជំងឺរលាកសួតធ្ងន់ធ្ងរនៅថ្ងៃច័ន្ទទី ០៥ ខែ តុលា។ ការអង្កេតកំពុងដំណើរការ ដើម្បីកំណត់នូវកត្តាប្រឈមមុខជាក់លាក់ទាំងឡាយដូចជា បញ្ហាសុខភាពពីមុន ដែលនាំអោយគាត់មានជំងឺធ្ងន់ធ្ងរពីការរាតត្បាតជាសកលនៃជំងឺ ផ្តាសាយថ្មី H1N1។

អ្នកជំងឺមានអាយុ ២៥ ឆ្នាំ ភេទ ស្រី មកពីទីក្រុងភ្នំពេញបានចាប់ផ្តើមចេញរោគសញ្ញានៃជំងឺផ្តាសាយពីថ្ងៃទី ២៣ ខែ កញ្ញា ហើយបានស្វែងរកការព្យាបាល នៅគ្លីនិកសម្ភពឯកជននៅទីក្រុងភ្នំពេញ។ នៅថ្ងៃច័ន្ទ ទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៩ គាត់ត្រូវបានដាក់អោយចូលសំរាកនៅគ្លីនិកសម្ភពឯកជនដដែលនោះ ដោយមានរោគសញ្ញា ក្តៅ និង ពិបាកដកដង្ហើម ហើយត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យកាល់ម៉ែតនៅ ថ្ងៃអង្គារ ទី ២៩ កញ្ញា ឆ្នាំ ២០០៩។ គាត់ត្រូវបានធ្វើរោគវិនិច្ឆ័យ ឃើញថា មានផ្ទុកវិរុសជំងឺរាតត្បាតប្រភេទថ្មី H1N1 នៅថ្ងៃទី ៣០ កញ្ញា ឆ្នាំ ២០០៩។

ក្រុមគ្រូពេទ្យនៅមន្ទីរពេទ្យកាល់ម៉ែតបានទទួលការជោគជ័យក្នុងការសង្គ្រោះជីវិតទារកដោយធ្វើការវះកាត់បន្ទាន់មួយនៅថ្ងៃទី ៤ ខែ តុលា ឆ្នាំ ២០០៩ នៅពេលដែលស្ថានភាពរបស់ស្ត្រីនោះកាន់តែដុនដាប។ បន្តមក ស្ត្រីនោះបានស្លាប់ដោយការរលាកសួតធ្ងន់ធ្ងរនៅថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០០៩ បន្ទាប់ពីមានការប្រឹងប្រែងព្យាលបាលយ៉ាងសកម្ម។ ដោយសារមានផ្ទៃពោះ ស្ត្រីរូបនេះស្ថិតក្នុងក្រុមដែលប្រឈមមុខខ្ពស់ ពីការកើតជំងឺធ្ងន់ធ្ងរបណ្តាលពីជំងឺផ្តាសាយថ្មី H1N1 ។

ឯកឧត្តម **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាលមានប្រសាសន៍ថា:

*"សំរាប់អ្នកជំងឺផ្តាសាយថ្មី H1N1 ភាគច្រើនគឺមានលក្ខណ:ស្រាល ហើយពួកគាត់នឹងជាសះស្បើយដោយមិនចាំបាច់មានការព្យាបាល ។ ប៉ុន្តែសំរាប់ក្រុមដែលប្រឈមមុខខ្ពស់ ជំងឺនេះអាចធ្ងន់ធ្ងរខ្លាំង ។ អ្នកមានជំងឺផ្តាសាយ និង មានជំងឺផ្សេងទៀតដូចជា: ជំងឺហឺត ជំងឺទឹកនោមផ្អែម ជំងឺបេះដូង ជំងឺថ្លើម ជំងឺក្រលៀន ជំងឺអេដស៍ និង ជំងឺរបេង ឬ មានផ្ទៃពោះ ត្រូវតែទៅពិគ្រោះជាមួយគ្រូពេទ្យជាបន្ទាន់ ជាពិសេសប្រសិនបើមានការពិបាកដកដង្ហើម ។"*

អនុលោមតាម **ផែនការណ៍ជាតិស្តីពីការទប់ស្កាត់ការរាតត្បាតជាសកលនៃរាជរដ្ឋាភិបាល** ក្រសួងសុខាភិបាលស្នើរអោយគ្រប់គ្រូពេទ្យឯកជនទាំងអស់ ដែលព្យាបាលអ្នកជំងឺផ្តាសាយ ហើយស្ថិតក្នុងក្រុមដែលប្រឈមមុខខ្ពស់ ត្រូវប្រញាប់ទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ១១៥ ដើម្បីក្រសួងសុខាភិបាលធ្វើការវាយតំលៃអ្នកជំងឺ និង ការអាចបញ្ជូនទៅកាន់មន្ទីរពេទ្យជាកំណត់ណាមួយ ។

មកដល់ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០៩ មានករណីដែលបញ្ជាក់ថាមានផ្ទុកវីរុសផ្តាសាយប្រភេទថ្មី H1N1 ចំនួន ១២០ ករណី នៅក្នុងប្រទេសកម្ពុជា ដោយមានការចំលងនៅក្នុងសហគមន៍ កើតឡើងនៅក្នុង ៨ ខេត្ត/រាជធានីគឺ ទីក្រុងភ្នំពេញ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពង់ស្ពឺ ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង និង ខេត្តស្វាយរៀង ។

មកដល់ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៩ នៅក្នុងពិភពលោក មានករណីដែលបានបញ្ជាក់ថាមានជំងឺ រាតត្បាតជាសកលនៃជំងឺផ្តាសាយថ្មី H1N1 លើសពី ៣៤០ ០០០ នាក់ កើតមាននៅក្នុងប្រទេសចំនួន ១៩១ ដែលរួមមាន ករណីស្លាប់ ៤១០០ នាក់ ។ ដោយប្រទេសកម្ពុជាក៏ដូចជាប្រទេសដទៃទៀតដែរ លើកទឹកចិត្តអ្នកដែលមានជំងឺផ្តាសាយស្រាល អោយសំរាកនៅផ្ទះ និង ព្យាលបាលដោយខ្លួនឯង គេរំពឹងទុកថាចំនួនពិតប្រាកដនៃករណីដែលបានរាយការណ៍ នឹងមិនឆ្លុះបញ្ចាំងពីការរាលដាលពិតប្រាកដនៅក្នុងប្រទេសទេ ។

ក្រសួងសុខាភិបាល បន្តរំលឹកដល់សមាជិកនៃសាធារណជនអោយសំរាកនៅផ្ទះ និង ជៀសវាងទៅកន្លែងដែលមានមនុស្សកកកុញ ប្រសិនបើមានរោគសញ្ញាស្រដៀងជំងឺផ្តាសាយ( ក្តៅខ្លួនលើសពី ៣៨អង្សាសេ ក្អក ឈឺបំពង់ក ឈឺក្បាល ឈឺសាច់ដុំ និង ឈឺខ្លួន) ។ មានតែអ្នកជំងឺផ្តាសាយប្រភេទថ្មី H1N1 ធ្ងន់ធ្ងរប៉ុណ្ណោះដែលត្រូវការសំរាកពេទ្យ ។

ក្រសួងសុខាភិបាលបន្តតាមដានសភាពការណ៍យ៉ាងជិតស្និត និង កំពុងធ្វើការ ដោយសហការជាមួយក្រសួងនានា ភ្នាក់ងារ និង ដៃគូអភិវឌ្ឍន៍ដទៃទៀតដើម្បីធានាការសំរប សំរួលសកម្មភាពអោយមានប្រសិទ្ធភាព សំរាប់សុខភាពសាធារណៈ និង សុវត្ថិភាព ។ វិធានការនានារួមមាន ការបន្តការតាមដាន រកអ្នកជំងឺ នៅតាមអាកាសយានដ្ឋានអន្តរជាតិទាំងអស់ និង ច្រកទ្វារព្រំដែន បង្កើនសមត្ថភាព មន្ទីរពេទ្យ បន្តយុទ្ធនាការអប់រំជាសាធារណៈ ជាពិសេសទាក់ទងទៅនិងការជួបជុំគ្នាជាសាធារណៈ ។

ក្រសួងសុខាភិបាល នឹងបន្តជូន ដំណឹងដល់សាធារណជនអំពីការ វិវត្តន៍របស់ជំងឺនេះ តាមរយៈគេហទំព័ររបស់នាយកដ្ឋាន ប្រយុទ្ធនឹងជំងឺឆ្លង www.cdcmoh.gov.kh ។

**ការណែនាំសំរាប់សាធារណៈជន**

**របៀបសំគាល់ជំងឺផ្តាសាយ និង វិធីត្រូវអនុវត្ត:**

**រោគសញ្ញានៃជំងឺផ្តាសាយថ្មី H1N1** ស្រដៀងនិងជំងឺផ្តាសាយតាមរដូវ និង រួមមាន: ក្តៅខ្លាំងលើសពី ៣៨ អង្សាសេ ក្អក ឈឺក្បាល ឈឺសាច់ដុំ ឈឺបំពង់ក ហៀរសំបោរ និង អស់កំលាំង។ ការចំលងរោគអាចចាប់ផ្តើមពី ១ ថ្ងៃ មុនចេញរោគសញ្ញា រហូត ៧ ថ្ងៃ ក្រោយចេញរោគសញ្ញា។

**ការព្យាបាលគឺដូចជំងឺផ្តាសាយតាមរដូវ** ហើយរួមមាន: ផឹកទឹកអោយបានច្រើន សំរាកនិងប្រើថ្នាំប៉ារ៉ាសេតាម៉ុល (Paracetamol) ដើម្បីបន្ថយកំដៅ និង ការឈឺសាច់ដុំ។

ករណីភាគច្រើន មិនចាំបាច់ប្រើឱសថប្រឆាំងវីរុសទេ។ សព្វថ្ងៃនេះ ពុំទាន់មានវ៉ាក់សាំងសំរាប់ជំងឺផ្តាសាយថ្មី H1N1 នៅឡើយទេ ហើយវ៉ាក់សាំងនេះនឹងមិនមានប្រើប្រាស់ជាទូលាយ នៅក្នុងរយៈពេលខ្លីខាងមុខនេះទេ។

**ការពារខ្លួនអ្នក និង គ្រួសារអ្នក:**

មធ្យោបាយដ៏មានប្រសិទ្ធភាព សំរាប់ការពារការរីករាលដាលនៃវីរុសជំងឺផ្តាសាយថ្មី H1N1 គឺត្រូវអនុវត្ត អោយបានល្អ និង ជាប្រចាំ នូវអនាម័យខ្លួនប្រាណជាមូលដ្ឋាន:

- ខ្ទប់មាត់ និង ច្រមុះ ជាមួយក្រដាស នៅពេលក្អក ឬ កណ្តាស និង បោះចោលនៅក្នុងធុងសំរាម
- លាងដៃអោយបានញឹកញាប់ ជាមួយសាប៊ូ និង ទឹក (ជាពិសេស បន្ទាន់ពីក្អក កណ្តាស និង មុនបរិភោគ)
- ហាមខាតស្តោះនៅទីសាធារណៈ។

សំរាប់ព័ត៌មានបន្ថែមទៀតអំពីជំងឺផ្តាសាយថ្មី H1N1 សូមទាក់ទងមកលេខទូរស័ព្ទទាន់ហេតុការណ៍:

**១១៥ (មិនគិតថ្លៃ)**

**០១២ ៤៨៨ ៩៨១**

**០៨៩ ៦៦៩ ៥៦៧**

សំរាប់ព័ត៌មានបន្ថែមទៀត សូមធ្វើការទាក់ទង:


**ក្រសួងសុខាភិបាល**

វេជ្ជបណ្ឌិត **សុខ ទូច**

ទូរស័ព្ទ: +៨៥៥ ០១២ ៨៥៦ ៨៤៨

វេជ្ជបណ្ឌិត **លី សូវ៉ាន់**

ទូរស័ព្ទ: + ៨៥៥ ០១២ ៨២៥ ៤២៤

**អង្គការសុខភាពពិភពលោក**

វេជ្ជបណ្ឌិត **Michel Thieren:**

ទូរស័ព្ទ: +៨៥៥ ០២៣ ២១៦ ៦១០

វេជ្ជបណ្ឌិត **Nima Asgari:**

ទូរស័ព្ទ: +៨៥៥ ០២៣ ២១៦ ៦១០